ក្រុមហ៊ុន ខេម ជីអេសអេម ម.ក




២០២៤

# របាយការណ៍
# ប្រចាំត្រីមាសទី៣

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២៤ (បានត្រួតពិនិត្យ) | ឆ្នាំ២០២៣ (បានធ្វើសវនកម្ម) |
|---|---|---|
| ទ្រព្យសកម្មសរុប | ២.៧២៧.៤១៨ | ២.៥៦០.៩៩៦ |
| បំណុលសរុប | ១.៥៤៤.៨៤២ | ១.៤៥៧.៥៣៨ |
| មូលធនសរុប | ១.១៨២.៥៧៦ | ១.១០៣.៤៥៨ |

| លទ្ធផលហិរញ្ញវត្ថុ (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២៤ (បានត្រួតពិនិត្យ) | ត្រីមាសទី៣ ឆ្នាំ២០២៣ (បានត្រួតពិនិត្យ) |
|---|---|---|
| ចំណូលសរុប | ១៧៤.០១២ | ១៨៦.០៩៣ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ៥.៦៥៣ | ៤២.២១៦ |
| ចំណេញ/(ខាត) ក្រោយបង់ពន្ធ | ៤.១៦៣ | ៣០.៧១០ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៤.១៣៦ | ៣០.៦០៦ |

| អនុបាតហិរញ្ញវត្ថុ | | ត្រីមាសទី៣ ឆ្នាំ២០២៤ (បានត្រួតពិនិត្យ) | ឆ្នាំ២០២៣ (បានធ្វើសវនកម្ម) |
|---|---|---|---|
| អនុបាតសាធនភាព (ដង) | | ០,៤៣ | ០,៤៣ |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត (%) | ៣១២% | ២២% |
| | អនុបាតចរន្តលឿន (%) | ៣៣% | ១៩% |
| | | ត្រីមាសទី៣ ឆ្នាំ២០២៤ (បានត្រួតពិនិត្យ) | ត្រីមាសទី៣ ឆ្នាំ២០២៣ (បានត្រួតពិនិត្យ) |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (%) | ០,២% | ១% |
| | អនុបាតចំណេញធៀបនឹងមូលធន (%) | ០,៤% | ៣% |
| | អនុបាតគម្លាតចំណេញដុល (%) | ៧៣% | ៧៥% |
| | អនុបាតគម្លាតចំណេញភាព (%) | ២% | ១៦% |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ២ | ១៦ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | | ៣ | ៣ |

# ក្រាហ្វិកអំពីព័ត៌មាន ហិរញ្ញវត្ថុសង្ខេប

## ស្ថានភាពហិរញ្ញវត្ថុ

### ទ្រព្យសកម្មសរុប
(ប៊ីលានរៀល)

+៦%

+១៦៦




ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ បានកើនឡើង ចំនួន៦% ឬ ១៦៦ ប៊ីលានរៀល ធៀបនឹង ឆ្នាំ២០២៣

### បំណុលសរុប
(ប៊ីលានរៀល)

+៦%

+៨៧




ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ បានកើនឡើង ចំនួន៦% ឬ៨៧ ប៊ីលានរៀល ធៀបនឹង ឆ្នាំ២០២៣

### មូលធនសរុប
(ប៊ីលានរៀល)

+៧%

+៨០




ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ បានកើនឡើងចំនួន ៧% ឬ ៨០ ប៊ីលានរៀល ធៀបនឹងឆ្នាំ២០២៣

## លទ្ធផលចំណូលលម្អិត ចំណេញឬខាត និងលទ្ធផលលម្អិតផ្សេងៗ

### ចំណូល
(ប៊ីលានរៀល)

-៦%

-១២




ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ មានការថយចុះចំនួន ៦% ឬ១២ ប៊ីលានរៀល ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣

### ចំណេញ/(ខាត) មុនបង់ពន្ធលើប្រាក់ចំនូល
(ប៊ីលានរៀល)

-៨៦%

-៣៦




ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ មានការថយចុះ ចំនួន ៨៦% ឬ ៣៦ ប៊ីលានរៀល ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣

### ចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ
(ប៊ីលានរៀល)

-៨៧%

-២៧




ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ មានការថយចុះចំនួន ៨៧% ឬ ២៧ ប៊ីលានរៀល ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣

### លទ្ធផលលម្អិតសរុប ក្នុងការិយបរិច្ឆេទ
(ប៊ីលានរៀល)

-៨៧%

-២៧




ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ មានការថយចុះចំនួន ៨៧% ឬ ២៧ ប៊ីលានរៀល ធៀបនឹងត្រីមាសទី៣ ឆ្នាំ ២០២៣

# សមាសភាពក្រុមប្រឹក្សាភិបាល



អ្នកឧញ៉ា គិត ម៉េង
ប្រធានក្រុមប្រឹក្សាភិបាល



លោក WILLIAM MARK HANNA
អភិបាលមិនប្រតិបត្តិ



លោក PAUL CAREY CLEMENTS
អភិបាលមិនប្រតិបត្តិ



លោក CHRISTOPHER DONALD TIFFIN
អភិបាលមិនប្រតិបត្តិ



លោកស្រី ហិប សិកា
អភិបាលឯករាជ្យ

# សេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



**ជូនចំពោះភាគហ៊ុនិកជាទីគោរព**

ខ្ញុំបាទ មានសេចក្តីសោមនស្សរីករាយក្នុងការចែករំលែក នូវលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន ខេម ជីអេសអេម ម.ក (“សែលកាត”) សម្រាប់ត្រីមាសទី៣ នៃឆ្នាំ២០២៤ នេះ។ ទោះបីជាជួបប្រទះបញ្ហាប្រឈមជាបន្តបន្ទាប់ ក្នុងវិស័យទូរគមនាគមន៍យ៉ាងណាក្តី ក៏ក្រុមហ៊ុន សែលកាត នៅតែរឹងមាំ និងបន្តរីកលូតលាស់គួរឱ្យកត់សម្គាល់ផងដែរ។

ជាមួយនឹងយុទ្ធសាស្ត្រក្នុងការពង្រីកទីផ្សារ រួមមានការពង្រីកកញ្ចប់សេវាអ៊ីនធឺណិតតាមផ្ទះ និងយុទ្ធនាការទីផ្សារដ៏មានភាពច្នៃប្រឌិត ក្រុមហ៊ុន សែលកាត បានទទួលលទ្ធផលគួរជាទីគាប់ចិត្ត។ ក្រុមហ៊ុនមានទ្រព្យសកម្មសរុប បានកើនឡើងដល់ ២.៧២៧ ប៊ីលានរៀល ដែលបានឆ្លុះបញ្ចាំងពីការវិនិយោគឥតឈប់ឈរ ទៅលើហេដ្ឋារចនាសម្ព័ន្ធបណ្តាញទូរគមនាគមន៍ និងការប្តេជ្ញាចិត្តក្នុងការពង្រីកនូវវិសាលភាព និងសេវារបស់ក្រុមហ៊ុនយើង។ ភាគហ៊ុនរបស់ភាគហ៊ុនិកក៏បានកើនឡើងពី ៧% ទៅ ១.១៨៣ ប៊ីលានរៀល ដែលការកើនឡើងនេះសបញ្ជាក់ពីស្ថេរភាពហិរញ្ញវត្ថុ និងភាពរឹងមាំរបស់ក្រុមហ៊ុនយើង។

ខណៈដែលប្រាក់ចំណូលរបស់ក្រុមហ៊ុន មានការប្រែប្រួលបន្តិចបន្តួចនៅត្រីមាសនេះ បានធ្វើឲ្យក្រុមហ៊ុនដាក់ចេញនូវយុទ្ធសាស្ត្រថ្មី ក្នុងការសម្របខ្លួនទៅនឹងបទប្បញ្ញត្តិនានា ដែលបានដាក់ចេញ ក៏ដូចជាការវិវត្តនៃទីផ្សារផងដែរ។ យើងមានទំនុកចិត្តថា យុទ្ធសាស្ត្របង្ការនេះ នឹងជួយឲ្យក្រុមហ៊ុនមាននិរន្តរភាព និងកំណត់ពីភាពជោគជ័យជាក់លាក់ របស់យើងនាពេលអនាគត។

ក្រុមហ៊ុន នៅតែបន្តការផ្តល់នូវគុណភាពសេវាកម្មល្អបំផុតជូនអតិថិជន តាមរយៈការពង្រឹងបណ្តាញទូរគមនាគមន៍ ការពង្រីកសេវាកម្មឌីជីថល និងបទពិសោធប្រើប្រាស់សេវាជូនអតិថិជនគួរជាទីទុកចិត្ត។ ការវិនិយោគទុនទាំងនេះនឹងធ្វើឲ្យក្រុមហ៊ុនមានប្រាក់ចំណេញគួរឲ្យកត់សម្គាល់នាពេលអនាគត ដែលធានាបានថា ក្រុមហ៊ុន សែលកាត នឹងនៅតែបន្តឈានមុខលើវិស័យទូរគមនាគមន៍ក្នុងប្រទេសកម្ពុជា។

ខ្ញុំបាទ សូមថ្លែងអំណរគុណ ចំពោះបុគ្គលិកក្រុមហ៊ុន អតិថិជន និងដៃគូ ចំពោះការគាំទ្រឥតងាករេមកលើ ក្រុមហ៊ុន សែលកាត។ យើងខ្ញុំ នឹងនៅតែបន្តជំរុញនូវនវានុវត្តន៍ ការពង្រីកបណ្តាញទូរគមនាគមន៍ និងការរួមចំណែកលើវឌ្ឍនភាពក្នុងវិស័យឌីជីថលរបស់ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុន សែលកាត មានទំនុកចិត្តថា ក្រុមហ៊ុននឹងមានសន្ទុះកើនឡើងក្នុងពេលឆាប់ៗនេះ។ ខ្ញុំបាទ នឹងធ្វើបច្ចុប្បន្នភាព នៃកើនឡើងរបស់ក្រុមហ៊ុនជូនអតិថិជន ក្នុងត្រីមាសខាងមុខនេះ។

ដោយក្តីគោរពអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤

ហត្ថលេខា និងត្រា




អ្នកឧកញ៉ា គិត ម៉េង

ប្រធានក្រុមប្រឹក្សាភិបាល

# មាតិកា


**ព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ i

**គ្រោងហិរញ្ញវត្ថុអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប** ........ ii

**សមាសភាពក្រុមប្រឹក្សាភិបាល** ........ iii

**សេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល** ........ iv

ផ្នែកទី ១៖ ព័ត៌មានទូទៅរបស់ក្រុមហ៊ុនចុះបញ្ជី ........ 1

ក. អត្តសញ្ញាណរបស់ក្រុមហ៊ុនចុះបញ្ជី ........ 1

ខ. លក្ខណៈនៃធុរកិច្ច ........ 1

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាស ........ 3

ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ........ 11

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ........ 11

ខ. រចនាសម្ព័ន្ធនៃចំណូលក្រុមហ៊ុន ........ 12

ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ ........ 14

ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ........ 15

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ........ 15

ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........ 18

គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ........ 19

ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ........ 19

ង. ផលប៉ះពាល់នៃអតិផរណា ........ 19

ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ........ 20

ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេលសម្រាប់រយៈពេល ៣ខែ និង៩ខែ បញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤ .... 22

## ផ្នែកទី ១៖ ព័ត៌មានទូទៅរបស់ក្រុមហ៊ុនចុះបញ្ជី

### ក. អត្តសញ្ញាណរបស់ក្រុមហ៊ុនចុះបញ្ជី

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ក្រុមហ៊ុន ខេម ជីអេសអេម ម.ក |
| ជាអក្សរឡាតាំង | CAMGSM PLC. |
| អក្សរកូដ | KH១០០០០២២០០០៩ |
| ទីស្នាក់ការ | ផ្ទះលេខ ២៤៦ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +(៨៥៥) ១២ ៨១២ ៨១២/៨១២ |
| លេខទូរសារ | គ្មាន |
| គេហទំព័រ | www.cellcard.com.kh |
| អ៊ីម៉ែល | investor_relations@cellcard.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១៥២៧៤ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៦ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណ | គ្មាន |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ០៦១/២៣ SERC/SSR ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣ ដោយនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) |
| ឈ្មោះបុគ្គលតំណាងក្រុមហ៊ុន | **លោក** Simon John Perkins |

### ខ. លក្ខណៈនៃធុរកិច្ច

ក្រុមហ៊ុន ខេម ជីអេសអេម ម.ក (ហៅកាត់ថា "ក្រុមហ៊ុន") និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលក្រុមហ៊ុនកាន់កាប់ (ត្រូវហៅជារួមថា"សម្ព័ន្ធ") គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើង នៅក្នុងព្រះរាជាណាចក្រកម្ពុជាក្រោមច្បាប់ស្តីពីការវិនិយោគបរទេស។ ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន ខេម ជីអេសអេម ម.ក ស្ថិតនៅអគារលេខ ២៤៦ មហាវិថី ព្រះមុនីវង្ស សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានទទួលលិខិតអនុម័តវិនិយោគលេខ ១០៦៦/៩៦ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាវិនិយោគកម្ពុជាចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៦។ ក្រុមហ៊ុនបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម និងបានទទួលលិខិតយោងលេខ២១៥៩ ព.ណ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៦។ វិញ្ញាបនបត្រចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មលេខ INV ២៣១E/១៩៩៦។

ក្រុមហ៊ុនត្រូវបានកាន់កាប់ភាគច្រើនដោយក្រុមហ៊ុន រ៉ូយ៉ាល់ មីលីខម ("RMC") ដែលមានការិយាល័យកណ្តាលស្ថិតនៅផ្ទះលេខ ២៤៦ H-I មហាវិថី ព្រះមុនីវង្ស រាជធានីភ្នំពេញ។ RMC គឺជាក្រុមហ៊ុនសម្ព័ន្ធអាជីវកម្ម រវាងក្រុមហ៊ុន Three Star Investment Cambodia Ltd., ជាក្រុមហ៊ុន ដែលបានចុះបញ្ជីនៅ Cayman Islands ដែលមានភាគហ៊ុន ៦១,៥% និងក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ដែលមាន

ភាគហ៊ុន ៣៨,៥%។

ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណផ្តល់សេវា និងធ្វើប្រតិបត្តិការទូរស័ព្ទចល័ត ឌីជីថល GSM នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩៦។ ក្រុមហ៊ុនបានទទួលកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណថ្មី នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលមានសុពលភាព ៣០ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាប័ណ្ណ និងអាចបន្តជាថ្មីសម្រាប់ថិរវេលាបន្ថែម ៥ឆ្នាំទៀត។ អាជ្ញាប័ណ្ណមួយសម្រាប់ប្រើប្រព័ន្ធ GSM និងការបែងចែកប្រេកង់ និងមួយទៀតប្រើសម្រាប់បច្ចេកវិទ្យា ៣G និងការបែងចែកប្រេកង់។ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណផ្តល់សេវា និងធ្វើប្រតិបត្តិការសេវាពិធីការសម្លេងតាមអ៊ីនធឺណិត (VoIP) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណសម្រាប់ការផ្តល់ និងប្រតិបត្តិការ ជាអ្នកផ្តល់សេវាអ៊ីនធឺណិត (ISP) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្ព័ន្ធប្រើប្រាស់ពាក្យ "Cellcard" ជាឈ្មោះយីហោរបស់ខ្លួន សម្រាប់ការតភ្ជាប់ទូរស័ព្ទចល័ត និងអ៊ីនធឺណិត។ នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណថ្មី ពីនិយ័តករទូរគមនាគមន៍កម្ពុជា សម្រាប់ប្រតិបត្តិការ និងការផ្តល់សេវាទូរស័ព្ទចល័តដោយប្រើបច្ចេកវិទ្យា ២G ៣G និង ៤G (LTE) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសុពលភាពរហូតដល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០៤៣។ អាជ្ញាប័ណ្ណថ្មីនេះ គឺជាការផ្ទេរពីអាជ្ញាប័ណ្ណដែលមានស្រាប់ចំនួនបី រួមមានអាជ្ញាប័ណ្ណចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ សម្រាប់ប្រតិបត្តិការ និងការផ្តល់សេវាទូរស័ព្ទចល័តដោយប្រើបច្ចេកវិទ្យា ២G ៣G និង ៤G (LTE) ដែលផ្តល់ទៅឲ្យក្រុមហ៊ុន មូបីតែល ខមភេនី លីមីធីត និងអាជ្ញាប័ណ្ណចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ សម្រាប់ប្រតិបត្តិការ និងការផ្តល់សេវាទូរស័ព្ទដោយការប្រើប្រាស់បច្ចេកវិទ្យា ៣G និងអាជ្ញាប័ណ្ណចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ សម្រាប់ប្រតិបត្តិការ និងការផ្តល់សេវាទូរស័ព្ទចល័តដោយប្រើបច្ចេកវិទ្យា GSM ៩០០ & ១៨០០ ដែលបានផ្តល់ជូនក្រុមហ៊ុន។ ក្រោមអាជ្ញាប័ណ្ណថ្មីនេះ ក្រុមហ៊ុនមានសិទ្ធិ ផ្តល់សេវាទូរគមនាគមន៍ចល័តដោយប្រើប្រាស់បច្ចេកវិទ្យា ២G ៣G និង ៤G (LTE) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាអាទិ៍ សេវាសម្លេង សេវាទិន្នន័យ សេវាអ៊ីនធឺណិត សេវាទូរស័ព្ទក្នុងស្រុក សេវាទូរស័ព្ទចម្ងាយឆ្ងាយ និងសេវាទូរស័ព្ទអន្តរជាតិ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធមានដូចខាងក្រោម៖

- ក្រុមហ៊ុន មូបីតែល ខមភេនី លីមីធីត ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន ខេម ជីអេសអេម ម.ក និងត្រូវបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៧ ដោយផ្អែកទៅតាមលិខិតយោងអាជ្ញាប័ណ្ណលេខ CO ២៨២៤E/១៩៩៧។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ក្រុមហ៊ុន មូបីតែល ខមភេនី លីមីធីត បានទទួលអាជ្ញាប័ណ្ណពីនិយ័តករទូរគមនាគមន៍កម្ពុជា `ន.ទ.ក.´ ដើម្បីធ្វើប្រតិបត្តិការបច្ចេកវិទ្យា `៤G´ ដែលជាបច្ចេកវិទ្យាសម្រាប់ការវិវត្តរយៈពេលវែង។ បច្ចុប្បន្នក្រុមហ៊ុន Mobitel មិនមានប្រតិបត្តិការទេ។

- ក្រុមហ៊ុន Everyday Company Limited ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន ខេម ជីអេសអេម ម.ក និងត្រូវបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០១ យោងទៅតាមអាជ្ញាប័ណ្ណ CO ៥៥៦១/០១P។ បច្ចុប្បន្ន ក្រុមហ៊ុន Everyday មិនមានប្រតិបត្តិការទេ។

- នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ក្រុមហ៊ុន ថេឡេម៉ូបាយ (ខេមបូឌា) ឧបករេសិន (ធីស៊ីស៊ី) ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ ក្រុមហ៊ុន ខេម ជីអេសអេម ម.ក។

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ ធីស៊ីស៊ី ទទួលបានអាជ្ញាប័ណ្ណពីនិយ័តករទូរគមនាគមន៍ដើម្បីប្រតិបត្តិការសេវាបង្គោលអង់តែន ក្នុងព្រះរាជាណាចក្រកម្ពុជា។

គ. **ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាស**

**ខែកក្កដា ឆ្នាំ២០២៤**

សម្រាប់អ្នកប្រើប្រាស់

- **ការបើកដំណើរការសាកល្បងនូវ មជ្ឈមណ្ឌលបទពិសោធអតិថិជន សែលកាត រ៉ូយ៉ាល់ វេលវេ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៤**
  ក្រុមហ៊ុន សែលកាត បានបើកបង្ហាញមជ្ឈមណ្ឌលបទពិសោធអតិថិជន សែលកាត រ៉ូយាល់ វេលវេ នៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២៤ ដែលអតិថិជនអាចស្វែងយល់ពីសេវាកម្មអតិថិជនរបស់ក្រុមហ៊ុន ជួបជាមួយភ្នាក់ងារធនាគារវីង ទទួលទានកាហ្វេពី Coffee Hub ទិញសំបុត្ររថភ្លើង និងប្រើប្រាស់សេវាកម្មផ្សេងៗទៀត។

- **ការផ្លាស់ប្តូរស៊ីម 4G LTE នៅក្នុងខេត្តព្រៃវែង**
  ដោយការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ក្នុងការធ្វើឲ្យប្រសើរឡើងនូវបទពិសោធអតិថិជន និងផ្តល់ការតភ្ជាប់កាន់តែល្អប្រសើរ និងមានល្បឿនលឿន ក្រុមហ៊ុន សែលកាត បានបើកដំណើរការស្តង់សម្រាប់អតិថិជន នៅក្នុងខេត្តព្រៃវែង ដើម្បីលើកទឹកចិត្តឲ្យអតិថិជនធ្វើការផ្លាស់ប្តូរស៊ីម ២G/៣G ទៅជាស៊ីម ៤G។

**សេវាកម្មសម្រាប់អតិថិជនតាមផ្ទះ**

- **ដំណើរការស្តង់សែលកាតហូមវ៉ាយហ្វាយតាមបុរី**
  ដើម្បីពង្រឹង ការយល់ដឹងនៃសេវាកម្មថ្មី Cellcard Home Wi-Fi និងទទួលបានអតិថិជនកាន់តែច្រើន ជាពិសេសនៅក្នុងបុរី ក្រុមហ៊ុន សែលកាត បានចាប់ផ្តើមដំណើរការស្តង់នៅក្នុងបុរីរៀងរាល់ចុងសប្តាហ៍ ជាមួយនឹងការផ្តល់ជូនពិសេស និងសកម្មភាពផ្សេងៗ។

**ផ្នែកសហគ្រាស**

- **កម្មវិធី វេទិកាអប់រំឌីជីថល**
  ក្រុមហ៊ុន សែលកាត មានកិត្តិយសក្នុងការសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើបទបង្ហាញក្នុងកម្មវិធី "វេទិកាអប់រំឌីជីថលឆ្នាំ ២០២៤" ដែលបានរៀបចំឡើង ដើម្បីបង្កើនវិធីសាស្ត្របង្រៀន បង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងលើកទឹកចិត្តដល់កិច្ចសហការ។

- **ការលើកកម្ពស់អាជីវកម្មរបស់អ្នក លើសពីការតភ្ជាប់ទំនាក់ទំនង**
  ដើម្បីបង្ហាញពីទស្សនីយភាពនៃកញ្ចប់សេវាកម្មផ្សេងៗ និងណែនាំពីសេវាកម្មសុវត្ថិភាព និងដំណោះស្រាយអំពីដៃគូ ដូចជាក្រុមហ៊ុន Microsoft និង NexusGuard ក្រុមហ៊ុន សែលកាត បានរៀបចំកម្មវិធីពង្រឹងបណ្តាញទំនាក់ទំនង សម្រាប់រាល់ក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុន រ៉ូយ៉ាល់គ្រុប។

ការដាក់បង្ហាញស្តង់ សែលកាត ហូមវ៉ាយហ្វាយ




ការផ្លាស់ប្តូរស៊ីម ៤G LTE នៅក្នុងខេត្តព្រៃវែង




វេទិកាអប់រំឌីជីថល




ការបើកដំណើរការសាកល្បង មជ្ឈមណ្ឌលបទពិសោធអតិថិជនសែលកាត រ៉ូយ៉ាល់ រេលវេ




ការលើកកម្ពស់អាជីវកម្មរបស់អ្នកលើសពីការតភ្ជាប់ទំនាក់ទំនង



ខែសីហា ឆ្នាំ២០២៤

សម្រាប់អ្នកប្រើប្រាស់

- **ការឧបត្ថម្ភលើការប្រកួតថ្នាក់ជាតិ លើការប្រណាំងទូកកម្រិតអន្តរជាតិ**
  ក្រុមហ៊ុនសែលកាត បានគាំទ្រការប្រកួតថ្នាក់ជាតិ លើការប្រណាំងទូកកម្រិតអន្តរជាតិ ជាមួយនឹងសកម្មភាពសប្បាយរីករាយ និងការផ្តល់ជូនពិសេសៗជាច្រើន។
- **ការផ្លាស់ប្តូរស៊ីមកាត 4G LTE នៅខេត្តកំពង់ស្ពឺ**
  ក្រុមហ៊ុនសែលកាត បានបន្តបើកដំណើរការស្តង់សម្រាប់អតិថិជន ដែលអាចឲ្យអតិថិជនមកប្តូរស៊ីម ២G/៣G ទៅជាស៊ីម ៤G សម្រាប់ការតភ្ជាប់កាន់តែប្រសើរ និងការតភ្ជាប់អ៊ីនធឺណិតល្បឿនលឿន។
- **យុទ្ធនាការភ្ជាប់គម្រោងដើម្បីឈ្នះរង្វាន់**
  អតិថិជនរបស់សែលកាត នឹងមានឱកាសឈ្នះរង្វាន់ រថយន្ត Tesla និងរង្វាន់ប្រចាំសប្តាហ៍ផ្សេងទៀត រួមមាន ម៉ូតូ Honda GIORNO+ កុំព្យូទ័រ Macbook Pro M3 និង Huawei Matepad នៅពេលភ្ជាប់គម្រោងសេរី+ $១,៥ /$៦ ឬ $១០។ យុទ្ធនាការនេះគឺជាយុទ្ធនាការ ដែលកំពុងដំណើរការជាមួយនឹងសកម្មភាព ATL/BTL រួមមាន Billboard/LED/Prize Display/Dealer POSM/Livestream & Talkshow។
- **ការតាំងពិព័រណ៍សហគមន៍ នៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ**

  ការតាំងពិព័រណ៍បង្ហាញ និងសកម្មភាពកម្សាន្តផ្សេងៗ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីពង្រឹងការយល់ដឹងលើបណ្តាញសេវាគ្របដណ្តប់ និងណែនាំពីផលិតផលសេវាកម្ម ដើម្បីជួយជំរុញការលក់។
- **ការបើកសម្ពោធជាផ្លូវការមជ្ឈមណ្ឌលបទពិសោធអតិថិជន សែលកាត រ៉ូយ៉ាល់ រេលវេ**
  ក្រុមហ៊ុន សែលកាត បើកសម្ពោធមជ្ឈមណ្ឌលបទពិសោធអតិថិជន សែលកាត រ៉ូយ៉ាល់ រេលវេ ដែលអតិថិជនអាចស្វែងយល់ពីសេវាកម្មអតិថិជនដ៏ទូលំទូលាយរបស់ក្រុមហ៊ុន ជួបជាមួយភ្នាក់ងារធនាគាររីង ទទួលទានកាហ្វេ របស់ Coffee Hub ទិញសំបុត្ររថភ្លើង និងប្រើប្រាស់សេវាកម្មផ្សេងៗទៀត។
- **ការបើកបង្ហាញទូតសុច្ឆន្ទៈ**
  ក្រុមហ៊ុន សែលកាត ក៏បានបើកបង្ហាញទូតសុច្ឆន្ទៈ ៣រូបទៀត ដូចជា ពេជ្រ សូលីកា ជាតារាចម្រៀងដ៏មានមានភាពល្បីល្បាញផ្នែកបទចម្រៀងមនោសញ្ចេតនា និងសោកសៅ។ ម៉ម ពេជ្ជរិទ្ធ តារាចម្រៀងដ៏មានទេពកោសល្យរបស់កម្ពុជា ដែលពូកែបញ្ចូលតន្ត្រីខ្មែរទៅក្នុងបទចម្រៀងសិល្បៈរបស់គាត់។ សុខ សម្បត្តិ យុវជនខ្មែរដែលមានទេពកោសល្យជាច្រើនដូចជា ការរាំ ការច្រៀង និងផលិតតន្ត្រី ហើយត្រូវបានគេស្គាល់ច្រើនពីសំណាក់យុវជនជំនាន់ក្រោយ។
- **ការលក់ឧបករណ៍នៅ សែលកាត រ៉ូយ៉ាល់ រេលវេ**
  ការលក់ឧបករណ៍ផ្សេងៗត្រូវបានដាក់លក់នៅ សែលកាត រ៉ូយ៉ាល់ រេលវេ ជាមួយការផ្តល់ជូនពិសេសៗ។
- **ស្វែងយល់អំពីអនាគតភាពនៃវិស័យអប់រំ**
  ក្រុមហ៊ុន សែលកាត មានមោទកភាពក្នុងការក្លាយជា អ្នកឧបត្ថម្ភផ្លាទីនីមនៃសន្និសីទជាតិប្រចាំឆ្នាំ២០២៤ ក្រោមប្រធានបទ "ស្វែងយល់អំពីអនាគតភាពនៃវិស័យអប់រំ ជាមួយនឹងគោលដៅរបស់យើងគឺលើកកម្ពស់ការអប់រំឌីជីថល តាមរយៈការអភិវឌ្ឍបច្ចេកវិទ្យាស្ថាប័នឌីជីថល"។

ការប្រកួតថ្នាក់ជាតិលើការប្រណាំងទូកកម្រិតអន្តរជាតិ




ការផ្លាស់ប្តូរស៊ីមកាត 4G LTE នៅខេត្តកំពង់ស្ពឺ




យុទ្ធនាការភ្ជាប់គម្រោងដើម្បីឈ្នះរង្វាន់




ការតាំងពិព័រណ៍សហគមន៍




ការលក់ឧបករណ៍




ស្វែងយល់អំពីអនាគតភាពនៃវិស័យអប់រំ



ពិធីសម្ពោធជាផ្លូវការ មជ្ឈមណ្ឌលបទពិសោធអតិថិជន សែលកាត រ៉ូយ៉ាល់ រេលវេ




ការបើកបង្ហាញទូតសុច្ឆន្ទៈ




សម្រាប់សហគ្រាស

- **អ្នកឧបត្ថម្ភផ្លាទីនីមនៃ វេទិកាសហគ្រិនធ្មើម និងពានរង្វាន់បណ្តាញសហគ្រិនស្ត្រីធ្មើមអាស៊ាន ២០២៤ (ថ្ងៃទី១ ខែសីហា ឆ្នាំ ២០២៤)**
  ក្រុមហ៊ុន សែលកាត មានកិត្តិយសជាអ្នកឧបត្ថម្ភផ្លាទីនីម នៃ "វេទិកាសហគ្រិនធ្មើម និងពានរង្វាន់បណ្តាញសហគ្រិនស្ត្រីធ្មើមអាស៊ាន ២០២៤ ក្រោមប្រធានបទ "អាស៊ានយើងតែមួយ-សាមគ្គីភាពកើតចេញពីភាពចម្រុះ" ដែលនឹងបង្ហាញពីទិដ្ឋភាពសហគ្រិនដ៏រស់រវើករបស់កម្ពុជា ដោយផ្តោតជាពិសេសលើសហគ្រាសដែលដឹកនាំដោយស្ត្រី។

- **សន្និសីទធនាគារនៅកម្ពុជាឆ្នាំ ២០២៤**
  ក្រុមហ៊ុន សែលកាត មានសេចក្តីរំភើបជាខ្លាំង ក្នុងការក្លាយជាដៃគូយុទ្ធសាស្ត្រនៃសន្និសីទធនាគារកម្ពុជាឆ្នាំ ២០២៤ ដែលរៀបចំដោយសមាគមធនាគារនៅកម្ពុជា។ ពួកយើងមានសេចក្តីរីករាយ ក្នុងការណែនាំការការពារ DDoS របស់យើង ដែលគ្របដណ្តប់លើការវាយប្រហារតាមអ៊ីនធឺណិត ការសិក្សាករណីរបស់ធនាគារសិង្ហបុរី និងដំណោះស្រាយសុវត្ថិភាពរបស់ Nexusguard ។

- **កម្មវិធីបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យស្តីពីទីផ្សារមូលបត្រនៅកម្ពុជា**
  ក្រុមហ៊ុន សែលកាត មានសេចក្តីសោមនស្សរីករាយ ដែលបានក្លាយជាអ្នកឧបត្ថម្ភធំនៅក្នុង "កម្មវិធីបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យស្តីពីទីផ្សារមូលបត្រនៅកម្ពុជា ដើម្បីចែករំលែកបទពិសោធ និងការយល់ដឹងអំពីការបោះផ្សាយមូលបត្រជាសាធារណៈរបស់ពួកយើង ធ្វើឲ្យមានផលវិជ្ជមាន និងពង្រឹងការប្តេជ្ញាចិត្តរបស់យើង ចំពោះចំណេះដឹងផ្នែកហិរញ្ញវត្ថុ។

វេទិកាសហគ្រិនផ្តើម និងពានរង្វាន់បណ្តាញសហគ្រិនស្ត្រីផ្តើមអាស៊ាន ២០២៤




សន្និសីទធនាគារនៅកម្ពុជាឆ្នាំ ២០២៤




កម្មវិធីបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យស្តីពីទីផ្សារមូលបត្រនៅកម្ពុជា




## ខែកញ្ញា ឆ្នាំ២០២៤

### សម្រាប់អ្នកប្រើប្រាស់

- **យុទ្ធនាការបញ្ចូលទឹកប្រាក់ & ឈ្នះរង្វាន់**
  ឱកាសឈ្នះមាស ១គីឡូ និងរង្វាន់មាសប្រចាំខែផ្សេងទៀតរួមមាន មាស ១ ដំឡឹង ខ្សែកមាស និងចិញ្ចៀនមាសសម្រាប់ការបញ្ចូលទឹកប្រាក់ចាប់ពី $១,៥ ឡើងទៅ។ យុទ្ធនាការនេះគឺជាយុទ្ធនាការ ដែលកំពុងបន្តជាមួយនឹងសកម្មភាព ATL/BTL រួមមាន Billboard/LED/Prize Display/Dealer POSM/Livestream & Talk show។
- **ការផ្លាស់ប្តូរស៊ីមកាត ៤G LTE ខេត្តកណ្តាល**
  ក្រុមហ៊ុន សែលកាត ក៏បន្តដំណើរការស្តង់សម្រាប់អតិថិជន ដែលពួកគេអាចមកប្តូរស៊ីម ២G/៣G ទៅជាស៊ីម ៤G សម្រាប់ការតភ្ជាប់កាន់តែប្រសើរ និងការតភ្ជាប់អ៊ីនធឺណិតល្បឿនលឿន។
- **ការផ្សព្វផ្សាយពីសេវាកម្មប៉ូមីង**

ដើម្បីអបអរពិធីបុណ្យធំៗក្នុងប្រទេសកម្ពុជា ចាប់ពីខែតុលា ដល់ខែធ្នូ ក្រុមហ៊ុន សែលកាត មានប្រូម៉ូសិន ដើម្បីផ្តល់ជូនកញ្ចប់បន្ថែមសម្រាប់ ASEAN Pack, Asia Pack និង Europe។

**សម្រាប់សេវាកម្មតាមផ្ទះ**

- **ការធ្វើឲ្យប្រសើរឡើងលើសេវាកម្មសែលកាតហូមវ៉ាយហ្វាយ**
  សែលកាតហូមវ៉ាយហ្វាយ កញ្ចប់គ្រួសារ បានដាក់ឲ្យដំណើរការកញ្ចប់ថ្មីមួយទៀត ដែលមានតម្លៃចាប់ពី $ ១៥ ដែលមានលក់ចាប់ពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៤។

**សម្រាប់សហគ្រាស**

- **ការពង្រឹងការអប់រំឌីជីថលសម្រាប់គ្រូបង្រៀននៅកម្ពុជា**
  នាយកដ្ឋានបរិវត្តកម្មឌីជីថល នៃក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយ ក្រុមហ៊ុន ខេម ជីអេសអេម ម.ក (សែលកាត) បានដាក់ដំណើរការកម្មវិធីមួយ ក្នុងគោលបំណងពង្រឹងកម្មវិធីបណ្តុះបណ្តាលគ្រូតាមបែបឌីជីថលនៅកម្ពុជា។
- **វេទិកាផ្នែកច្បាប់អន្តរជាតិសម្រាប់នគរបាលយុត្តិធម៌**
  ក្រុមហ៊ុន សែលកាត និង អ៊ីហ្សីខម មានមោទកភាពក្នុងការសហការឧបត្ថម្ភវេទិកាផ្នែកច្បាប់អន្តរជាតិសម្រាប់នគរបាលយុត្តិធម៌ ដែលរៀបចំដោយអង្គភាពការពារកុមារ។ វេទិកានេះផ្តោតលើការដោះស្រាយបញ្ហាសំខាន់ៗ និងបញ្ហាប្រឈមផ្លូវច្បាប់ទាក់ទងនឹងការរំលោភបំពានកុមារ និងឧក្រិដ្ឋកម្មដែលប៉ះពាល់ដល់ប្រទេសកម្ពុជា។

**យុទ្ធនាការបញ្ចូលទឹកប្រាក់ & ឈ្នះរង្វាន់**




**ការតាំងពិព័រណ៍សហគមន៍ខេត្តបាត់ដំបង**



ការពង្រឹងការអប់រំឌីជីថលសម្រាប់គ្រូបង្រៀននៅកម្ពុជា



ការធ្វើឲ្យប្រសើរឡើងលើសេវាកម្មសែលកាតហូមវ៉ាយហ្វាយ




ការផ្លាស់ប្ដូរស៊ីមកាត ៤G LTE ខេត្តកណ្ដាល




វេទិកាផ្នែកច្បាប់អន្តរជាតិសម្រាប់នគរបាលយុត្តិធម៌




ការផ្សព្វផ្សាយពីសេវាកម្មរ៉ូមីង



## ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក. លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

ក្រុមហ៊ុន ខេម ជីអេសអេម បានធ្វើឱ្យមានការវិវឌ្ឍយ៉ាងរីកចម្រើនក្នុងការពង្រីកហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីបំពេញតម្រូវការអតិថិជនដែលកំពុងកើនឡើង និងផ្តល់នូវសេវាកម្មដែលមានគុណភាពឈានមុខ។ គំនិតផ្តួចផ្តើមសំខាន់ៗរួមមាន ការពង្រីកបណ្តាញខ្សែកាប្លិ៍ ការសាងសង់កន្លែងថ្មីដើម្បីពង្រីកការគ្របដណ្តប់ ការធ្វើឱ្យប្រសើរឡើងដើម្បីបង្កើនសមត្ថភាពនៅទីតាំងដែលមានស្រាប់ ការផ្លាស់ប្តូរបន្តពីបច្ចេកវិទ្យា ៣G ទៅ ៤G និងការដាក់ឱ្យប្រើប្រាស់សេវាកម្ម VoLTE ។ ក្រុមហ៊ុន ខេម ជីអេសអេម ក៏កំពុងកាត់បន្ថយយ៉ាងសកម្មនូវការចំណាយប្រតិបត្តិការ និងការលើកកម្ពស់ការអនុវត្តប្រកបដោយនិរន្តរភាពផងដែរ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះបង្ហាញពីការយកចិត្តទុកដាក់របស់ក្រុមហ៊ុន ខេម ជីអេសអេម ក្នុងការផ្តល់នូវសេវាទូរគមនាគមន៍ ដែលអាចទុកចិត្តបាន ប្រសិទ្ធភាព និងភាពរួចរាល់នាពេលអនាគតនៅក្នុងប្រទេសកម្ពុជា។

#### ១. បណ្តាញទូរស័ព្ទចល័ត និងការពង្រីកខ្សែកាប្លិ៍អុបទិក

ដើម្បីបំពេញនូវតម្រូវការដែលមានចរាចរខ្ពស់ ក្រុមហ៊ុន ខេម ជីអេសអេម បានពង្រីកបណ្តាញរបស់ខ្លួនយ៉ាងសកម្ម ដោយធ្វើឲ្យប្រសើរឡើងនូវទីតាំងដែលមានស្រាប់ចំនួន ១០០ ឲ្យកាន់តែមានសមត្ថភាពខ្ពស់ និងបន្ថែមទីតាំងថ្មី ដើម្បីសម្រួលដល់ការគ្របដណ្តប់នៅខេត្តព្រះសីហនុ រាជធានីភ្នំពេញ កោះកុង ស្វាយរៀង កំពង់ធំ សៀមរាប ពោធិ៍សាត់ បាត់ដំបង និងបន្ទាយមានជ័យ។ ទន្ទឹមនឹងតម្រូវការរបស់ស្ថានីយ៍វិទ្យុ ក្រុមហ៊ុន ខេម ជីអេសអេម បានពង្រីកការភ្ជាប់បណ្តាញខ្សែកាប្លិ៍ ៦% ។

#### ២. ការផ្លាស់ប្តូរពី ៣G ទៅពង្រឹងសេវា ៤G

នៅក្នុងការផ្លាស់ប្តូរយុទ្ធសាស្ត្រពង្រឹងបណ្តាញសេវា ក្រុមហ៊ុន ខេម ជីអេសអេម បានបិទផ្អាកសេវាកម្ម ៣G នៅខេត្តព្រៃវែង កំពង់ស្ពឺ និងខេត្តកណ្តាល។ ការផ្អាកធនធានវិសាលគមនេះ អនុញ្ញាតឱ្យមានការវិនិយោគកាន់តែច្រើនក្នុងការពង្រីកសេវា ៤G។ បច្ចុប្បន្ននេះ អតិថិជនអាចទទួលបានអត្ថប្រយោជន៍ពីល្បឿនទិន្នន័យកាន់តែលឿន ការគ្របដណ្តប់កាន់តែទូលំទូលាយ និងទទួលបទពិសោធការប្រើប្រាស់ទូរស័ព្ទចល័តកាន់តែគួរឲ្យទុកចិត្ត។

#### ៣. ការអនុវត្ត VoLTE សម្រាប់ការពង្រឹងសេវាសម្លេង

ក្រុមហ៊ុន ខេម ជីអេសអេម បានអនុវត្តបច្ចេកវិទ្យា Voice over LTE (VoLTE) នៅទូទាំងបណ្តាញរបស់ខ្លួន ដោយផ្តល់ឲ្យអតិថិជននូវគុណភាពសំឡេងនៅកម្រិតខ្ពស់ និងពេលវេលាភ្ជាប់ការហៅទូរស័ព្ទលឿនជាងមុន។ ការផ្តល់សេវា VoLTE បានឈានដល់ ៦០% នៃអតិថិជនសរុប ដែលឆ្លុះបញ្ចាំងពីការប្រើប្រាស់យ៉ាងសកម្ម។ ភាពជឿនលឿននេះ មិនត្រឹមតែធ្វើឲ្យប្រសើរឡើងនូវបទពិសោធអ្នកប្រើប្រាស់ទូទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់បណ្តាញ ៤G ផងដែរ ដោយធានាបាននូវការផ្តល់សេវាកាន់តែប្រសើរ និងប្រសិទ្ធភាពបណ្តាញកាន់តែទូលំទូលាយ។

#### ៤. ការអនុវត្តស៊ីញ៉ាល់ NG Firewall សម្រាប់ពង្រឹងសុវត្ថិភាព

ក្រុមហ៊ុន ខេម ជីអេសអេម បានដាក់ពង្រាយដោយជោគជ័យ នូវដំណោះស្រាយស៊ីញ៉ាល់ Firewall ជំនាន់ចុងក្រោយនៅទូទាំងហេដ្ឋារចនាសម្ព័ន្ធបណ្តាញទំនាក់ទំនងរបស់ខ្លួន ដើម្បីពង្រឹងនូវសុវត្ថិភាពប្រឆាំងនឹងការគំរាម

កំហែងផ្នែកទូរគមនាគមន៍ដែលកំពុងកើតមាន។ ប្រព័ន្ធកម្រិតខ្ពស់នេះផ្តល់នូវការការពារយ៉ាងទូលំទូលាយ សម្រាប់អតិថិជន ព្រមទាំងបណ្តាញទ្រព្យសកម្ម ដោយការត្រួតពិនិត្យ និងតម្រងចរាចរស៊ីញ៉ាល់ដែលអាចកើតមាន។ ការអនុវត្តសម្រេចបាន៖

ក. **ការការពារ SS7៖** បានពង្រឹងសុវត្ថិភាពប្រឆាំងនឹងការវាយប្រហារដែលមានមូលដ្ឋានលើ SS7 ដោយធានានូវទំនាក់ទំនងអន្តរកម្មជាមួយដៃគូអន្តរជាតិ។

ខ. **សុវត្ថិភាពអង្គត់ផ្ចិត៖** ការការពារកាន់តែប្រសើរឡើងសម្រាប់ស៊ីញ៉ាល់ ៤G Protocols ធានាការបញ្ជូនទិន្នន័យប្រកបដោយសុវត្ថិភាព

គ. **សមាហរណកម្មការវិភាគ៖** ការត្រួតពិនិត្យពេលវេលាជាក់ស្តែង និងសមត្ថភាពរកឃើញការគំរាមកំហែងដែលអនុញ្ញាតឲ្យមានវិធានការសុវត្ថិភាពសកម្ម

ឃ. **ការអនុលោម៖** ស្របតាមស្តង់ដារសុវត្ថិភាពទូរគមនាគមន៍អន្តរជាតិ និងតម្រូវការបទប្បញ្ញត្តិ

ង. ការដាក់ពង្រាយស៊ីញ៉ាល់ NG Firewall បង្ហាញពីការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុន ខេម ជីអេសអេម ក្នុងការរក្សាសុវត្ថិភាពបណ្តាញ និងការការពារឯកជនភាពរបស់អ្នកប្រើប្រាស់ ខណៈពេលដែលរៀបចំហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន សម្រាប់បញ្ហាប្រឈមសុវត្ថិភាពនាពេលអនាគត។ ការវិនិយោគនេះពង្រឹងជំហររបស់ក្រុមហ៊ុន ខេម ជីអេសអេម ក្នុងនាមជាអ្នកឈានមុខ ក្នុងសេវាកម្មទូរគមនាគមន៍ដែលមានសុវត្ថិភាពនៅក្នុងប្រទេសកម្ពុជា។

### ៥. ការកាត់បន្ថយថ្លៃដើមប្រតិបត្តិការ និងគំនិតផ្តួចផ្តើមនិរន្តរភាព

ក្រុមហ៊ុន ខេម ជីអេសអេម នៅតែប្តេជ្ញាចិត្តក្នុងការសន្សំថ្លៃដើមប្រតិបត្តិការ និងនិរន្តរភាពបរិស្ថាន ជាមួយនឹងសមិទ្ធផលសំខាន់ៗរួមមាន:

- ការតភ្ជាប់បណ្តាញ៖ បច្ចុប្បន្នជាង ៩៨% នៃបណ្តាញត្រូវបានដំណើរការដោយបណ្តាញអគ្គិសនី បង្កើនប្រសិទ្ធភាពប្រតិបត្តិការ ការសន្សំការចំណាយ និងអត្ថប្រយោជន៍បរិស្ថាន។
- Off-Grid (Solar + Diesel Generator): ការពឹងផ្អែកលើម៉ាស៊ីនម៉ាស៊ូតបានធ្លាក់ចុះមកត្រឹម ២% នៃបណ្តាញ កាត់បន្ថយចំណាយប្រតិបត្តិការ ធ្វើឲ្យប្រសើរឡើងនូវភាពជឿជាក់ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន។
- Off-Grid (Solar + Battery)៖ ដំណោះស្រាយ Off-Grid (Solar + Baterry) ដោយគ្មានម៉ាស៊ីនម៉ាស៊ូតបានពង្រីកបណ្តាញដល់ទៅ ០,៦៦% ដោយផ្តល់នូវតម្លៃស្រដៀងគ្នា និងអត្ថប្រយោជន៍ បរិស្ថាន។

តាមរយៈគំនិតផ្តួចផ្តើមទាំងនេះ ក្រុមហ៊ុន ខេម ជីអេសអេម ពង្រឹងការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការលើកកម្ពស់ការតភ្ជាប់ កាត់បន្ថយការចំណាយ និងការជំរុញការអនុវត្តប្រកបដោយនិរន្តរភាព នៅក្នុងវិស័យទូរគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា។

## ខ. រចនាសម្ព័ន្ធនៃចំណូលក្រុមហ៊ុន

សូមពិនិត្យព័ត៌មានពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃចំណូលក្រុមហ៊ុន ដូចមានក្នុងតារាងខាងក្រោម។ សម្រាប់ព័ត៌

មានលម្អិត និងការបញ្ជាក់បន្ថែម សូមពិនិត្យផ្នែកទី៤ នៃរបាយការណ៍នេះ។

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៣ - ឆ្នាំ២០២៤ | | ត្រីមាសទី៣ - ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| ១ | ការផ្តល់សេវាទូរគមនាគមន៍ | ១៦៨.១៤៥ | ៩៧% | ១៨១.២៧៥ | ៩៧% |
| ២ | ចំណូលពីការភ្ជាប់សេវា និង ចំណូលពីការជាវសេវា | ៤.៥៣៥ | ២% | ៣.៨៩៧ | ២% |
| ៣ | ចំណូលពីបរិក្ខារ | ១៧ | 0% | - | 0% |
| ៤ | ចំណូលផ្សេងៗ | ១.៣១៥ | ១% | ៩២១ | ១% |
| **ចំណូលសរុប** | | **១៧៤.០១២** | **១០០%** | **១៨៦.០៩៣** | **១០០%** |

ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេលសម្រាប់រយៈពេល ៣ខែ និង៩ខែ បញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤ ដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

## ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ ផ្តោតលើលទ្ធផលនៃប្រតិបត្តិការ និងហិរញ្ញវត្ថុ ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុ**រួមចន្លោះពេល** គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤ ដែលបានត្រួតពិនិត្យដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុ**រួមចន្លោះពេល** ត្រូវបានរៀបចំឡើងស្របតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"។ មានតែសមាសធាតុសំខាន់ៗ នៃរបាយការណ៍ហិរញ្ញវត្ថុរួមចន្លោះពេល និងកត្តាសំខាន់ៗដែលបានជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ក្រុមហ៊ុន ខេម ជ្ជីអេសអេម តែប៉ុណ្ណោះទេ ដែលនឹងយកមកពិភាក្សា។

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១. ការវិភាគចំណូល

ចំណូលចម្បងរបស់ក្រុមហ៊ុន ខេម ជ្ជីអេសអេម គឺបានមកពីការផ្តល់សេវាទូរគមនាគមន៍ ការតភ្ជាប់និងទិញសេវា ពីបរិក្ខារ និងចំណូលផ្សេងៗ។

i. **ចំណូលពីការផ្តល់សេវាទូរគមនាគមន៍៖** រួមមានកម្រៃ ដែលបានពីការប្រើប្រាស់សេវាទូរស័ព្ទ កម្រៃភ្ជាប់សេវាទំនាក់ទំនង កម្រៃភ្ជាប់សេវារ៉ូមមីង និងសេវាទូរគមនាគមន៍ផ្សេងៗដូចជា សេវាទិន្នន័យ សេវាបញ្ជូនសារខ្លីៗ និងសេវាតម្លៃបន្ថែមផ្សេងៗ។

ii. **ចំណូលពីការភ្ជាប់ និងការទិញសេវា៖** រួមមានកម្រៃដែលបានពីការទិញសេវា និងការលក់ស៊ីមកាត និងថិរវេលាប្រើប្រាស់ដែលបានផ្ទុកជាមុន។

iii. **ចំណូលពីបរិក្ខារ៖** គឺរួមមានកម្រៃដែលបានពីការលក់ឧបករណ៍អ៊ីនធឺណិត ទូរស័ព្ទ និងបរិក្ខារ។

iv. **ចំណូលផ្សេងៗ៖** គឺចំណូលពីការលក់លេខស៊ីមកាតពិសេស និងសេវាកម្មផ្សេងទៀតដែលរួមបញ្ចូលទាំងចំណូលផ្សេងទៀតដែលមិនកើតឡើងដដែលៗផ្សេងទៀត (non-recurring revenue)។

#### ២. ការវិភាគចំណូលតាមផ្នែក

| លរ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៣ - ឆ្នាំ២០២៤ | | ត្រីមាសទី៣ - ឆ្នាំ២០២៣ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ | % | ចំនួនទឹកប្រាក់ | % |
| ១ | ចំណូលពីការផ្តល់សេវាទូរគមនាគមន៍ | ១៦៨.១៤៥ | ៩៧% | ១៨១.២៧៥ | ៩៧% |
| ២ | ចំណូលពីការភ្ជាប់ និងការទិញសេវា | ៤.៥៣៥ | ២% | ៣.៨៩៧ | ២% |
| ៣ | ចំណូលពីបរិក្ខារ | ១៧ | 0% | - | 0% |
| ៤ | ចំណូលផ្សេងៗ | ១.៣១៥ | ១% | ៩២១ | ១% |
| **ចំណូលសរុប** | | **១៧៤.០១២** | **១០០%** | **១៨៦.០៩៣** | **១០០%** |

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ ចំណូលសរុបថយចុះចំនួន ១២.០៨១ លានរៀល ឬ ៦% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣ ដែលបណ្ដាលមកពីការថយចុះ នៃចំណូលពីការផ្តល់សេវាទូរគមនាគមន៍ចំនួន ១៣.១៣០ លានរៀល ឬ ៧%។

## ៣. ការវិភាគគម្លាតចំណេញដុល

គម្លាតចំណេញដុល បន្តរក្សាស្ថិរភាពជាមួយអត្រា ៧៣% នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៤។

## ៤. ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២៤ | ត្រីមាសទី៣ ឆ្នាំ២០២៣ | បម្រែបម្រួល | |
|---|---|---|---|---|
| | | | ចំនួនទឹកប្រាក់ | % |
| **ចំណូល** | **១៧៤.០១២** | **១៨៦.០៩៣** | **(១២.០៨១)** | **(៦%)** |
| **ចំណាយប្រតិបត្តិការ** | | | | |
| ចំណាយរំលស់លើទ្រព្យសកម្មរូបីនិងអរូបី | (៣៣.៨៩២) | (៣៨.៩៧៥) | (៥.០៨៣) | (១៣%) |
| ចំណាយភ្ជាប់បណ្ដាញទូរស័ព្ទឆ្លងប្រព័ន្ធ | (៣.០៨៥) | (៣.១៣៣) | (៤៨) | (២%) |
| ចំណាយបុគ្គលិក | (១៦.២៣២) | (១៤.២២១) | ២.០១១ | ១៤% |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៨៦.៧០៨) | (៨១.០៣៤) | ៥.៦៧៤ | ៧% |
| ចំណេញ(ខាត)ផ្សេងៗ - សុទ្ធ | (១.០៤១) | ៨០៩ | ១.៨៥០ | ២២៩% |
| **ចំណេញប្រតិបត្តិការ** | **៣៣.០៥៤** | **៤៩.៥៣៩** | **(១៦.៤៨៥)** | **(៣៣%)** |
| ចំណូលហិរញ្ញវត្ថុ | ៧១១ | ២២.៨៣១ | (២២.១២០) | (៩៧%) |
| ចំណាយហិរញ្ញវត្ថុ | (២៨.១១២) | (៣០.១៥៤) | (២.០៤២) | (៧%) |
| **ចំណេញមុនពន្ធលើប្រាក់ចំណូល** | **៥.៦៥៣** | **៤២.២១៦** | **(៣៦.៥៦៣)** | **(៨៧%)** |

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ ប្រាក់ចំណេញប្រតិបត្តិការ មានការថយចុះចំនួន ១៦.៤៨៥ លានរៀល ឬ ៣៣% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣ ដោយសារការថយចុះ នៃប្រាក់ចំណូលជាមួយនឹង ការកើនឡើងចំណាយប្រតិបត្តិការផ្សេងៗ។ ប្រាក់ចំណេញមុនពន្ធលើប្រាក់ចំណូលថយចុះ ក្នុងចំនួន ៣៦.៥៦៣ លានរៀល ឬ ៨៧% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣ ដោយសារការថយចុះនៃចំណូលហិរញ្ញវត្ថុ និងប្រាក់ចំណេញប្រតិបត្តិការក្នុងត្រីមាសទី៣ ឆ្នាំ២០២៤។

## ៥. ការវិភាគចំណេញ/(ខាត) ក្រោយបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២៤ | ត្រីមាសទី៣ ឆ្នាំ២០២៣ | បម្រែបម្រួល | |
|---|---|---|---|---|
| | | | ចំនួនទឹកប្រាក់ | % |
| **ចំណេញមុនពន្ធលើប្រាក់ចំណូល** | **៥.៦៥៣** | **៤២.២១៦** | **(៣៦.៥៦៣)** | **(៨៧%)** |
| (ចំណាយ)/ឥណទានពន្ធលើប្រាក់ចំណូល | (១.៤៩០) | (១១.៥០៦) | (១០.០១៦) | (៨៧%) |
| **ចំណេញក្នុងការិយបរិច្ឆេទ** | **៤.១៦៣** | **៣០.៧១០** | **(២៦.៥៤៧)** | **(៨៦%)** |

ក្រុមហ៊ុន ខេម ជ្ជីអេសអេម មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលក្នុងអត្រា ២០% លើប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាក្នុងអត្រា ១% នៃផលរបរស្របតាមច្បាប់ស្តីពីពន្ធដារ។ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៤ ក្រុមហ៊ុន ខេម ជ្ជីអេសអេម បានទទួលលិខិតលេខ ៩៧២៦ ពីអគ្គនាយកដ្ឋានពន្ធដារ ដែលអនុញ្ញាតចំពោះការអនុគ្រោះពន្ធលើប្រាក់ចំណូលចំនួន ៣ឆ្នាំ សម្រាប់ឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥។ ការអនុគ្រោះនេះ យកវិធីគណនានៃការអនុគ្រោះពន្ធលើប្រាក់ចំណូល ដែលមានប្រភាគថយចុះស្របតាមតារាង ដែលមានក្នុងឧបសម្ព័ន្ធនៃអនុក្រឹត លេខ៤២ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។ អគ្គនាយកដ្ឋានពន្ធដារ ក៏បានអនុញ្ញាតការផ្អាកជាបណ្តោះអាសន្ន ចំពោះការបង់ពន្ធប្រាក់ចំណូលប្រចាំខែជាមុន សម្រាប់រយៈពេលនៃការអនុគ្រោះពន្ធលើប្រាក់ចំណូល។

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ ក្រុមហ៊ុន ខេម ជ្ជីអេសអេម បានរាយការណ៍ពីប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលមានចំនួន ៤.១៦៣ លានរៀល ថយចុះចំនួន ២៦.៥៤៧ លានរៀល ស្មើនឹង ៨៦% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣។ ការថយចុះនៃប្រាក់ចំណេញក្នុងការិយបរិច្ឆេទ បណ្តាលមកពីការថយចុះនៃចំណូលហិរញ្ញវត្ថុ និងប្រាក់ចំណេញប្រតិបត្តិការក្នុងត្រីមាស ទី៣ ឆ្នាំ២០២៤។

## ៦. ការវិភាគចំណូលលម្អិតសរុប(ខាត)

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី៣ ឆ្នាំ២០២៤ | ត្រីមាសទី៣ ឆ្នាំ២០២៣ | បម្រែបម្រួល | |
|---|---|---|---|---|
| | | | ចំនួនទឹកប្រាក់ | % |
| **ចំណេញក្នុងការិយបរិច្ឆេទ** | **៤.១៦៣** | **៣០.៧១០** | **(២៦.៥៤៧)** | **(៨៦%)** |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | |
| *ខ្ទង់ដែលមិនត្រូវចាត់ថ្នាក់ឡើងវិញ* | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | (២៧) | (១០៤) | ៧៧ | (៧៤%) |
| **លទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **៤.១៣៦** | **៣០.៦០៦** | **(២៦.៤៧០)** | **(៨៦%)** |

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ ក្រុមហ៊ុន ខេម ជ្ជីអេសអេម បានប្រកាសលទ្ធផលលម្អិតសរុបក្នុងការិយបរិច្ឆេទចំនួន ៤.១៣៦ លានរៀល ដែលថយចុះចំនួន ២៦.៤៧០ លានរៀល ស្មើនឹង ៨៦% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣។ ការកើនឡើងនេះបណ្តាលមកពីការថយចុះនៃចំណូលហិរញ្ញវត្ថុ និងប្រាក់ចំណេញប្រតិបត្តិការ

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤។

### ៧. ការវិភាគលើកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន បានទទួលរងផលប៉ះពាល់ពីការរួមបញ្ចូលគ្នានៃច្បាប់ និងបទបញ្ញត្តិថ្មីរបស់និយ័តករ និងកត្តាផ្សេងៗដូចជា ការប្រកួតប្រជែង កត្តាបរិស្ថាន សារពើពន្ធ និងកត្តាអង្គភាពនានា។ បើទោះបីជា ក្រុមហ៊ុនយើងខ្ញុំ កំពុងតែងើបឡើងវិញក្រោយពីវិបត្តិរីករាតត្បាតនៃ ជំងឺកូវីដ-១៩ ក៏ដោយ ក្រុមហ៊ុន ខេម ជីអេសអេម នៅមិនទាន់ឈានដល់ ស្ថានភាពធុរកិច្ចអន្តរជាតិដូចដើមពេញលេញនៅឡើយ។ ចំណូលរបស់ក្រុមហ៊ុន ក៏ត្រូវបានប៉ះពាល់ដោយស្ថានភាពសេដ្ឋកិច្ចអន្តរជាតិ ច្បាប់ និងបទប្បញ្ញត្តិថ្មីៗ ពាក់ព័ន្ធនឹងការផ្តល់សេវាផលិតផលផងដែរ។ ទោះយ៉ាងណាក៏ដោយ ដោយមានសេវាតភ្ជាប់ពេញលេញ សម្រាប់ទាំងតម្រូវការផ្ទាល់ខ្លួន និងតម្រូវការសាជីវកម្ម ក្រុមហ៊ុន ខេម ជីអេសអេម នៅតែបន្តជំរុញកំណើនហិរញ្ញវត្ថុ តាមរយៈសេវាទូរស័ព្ទចល័ត និងសេវាជីវភាពឌីជីថល ព្រមទាំងបន្តបង្កើនការគ្របដណ្តប់បណ្តាញ និងគុណភាពជាបន្តបន្ទាប់ ដើម្បីបម្រើអតិថិជនឲ្យបានកាន់តែប្រសើរ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងផ្គត់ផ្គង់

- **ការជះឥទ្ធិពលលើប្រាក់ចំណូលឆ្នាំ២០២៤៖** ប្រាក់ចំណូលត្រីមាសទី៣ ឆ្នាំ២០២៤ ត្រូវបានជះឥទ្ធិពលដោយការធ្លាក់ចុះនៃប្រាក់ចំណូលដែលការធ្លាក់ចុះនៃសេវាតាមរដូវកាល និងការផ្តាច់សេវាបន្ថែមមួយចំនួន។
- **កំណើនរបស់អ្នកប្រើប្រាស់៖** ក្នុងត្រីមាសទី៣ ក៏បានឃើញពីភាពធ្លាក់ចុះនៃអតិថិជន Postpaid និងកំណើននៃផលិតផលសេវាកម្មអ៊ីនធឺណិត ដោយមានឈ្មោះថា សែលកាត ហូមវ៉ាយហ្វាយ (Cellcard Home Wifi)។ ផលិតផលអ៊ីនធឺណិតដោយខ្សែកាប្លិ៍អុបទិក ទៅតាមផ្ទះ ត្រូវបានចាប់ផ្តើមដំណើរការឡើងវិញក្រោមឈ្មោះ Cellcard Home Wifi ក្នុងខែមេសា ឆ្នាំ ២០២៤។
- **ការបញ្ចូលទឹកប្រាក់តាមអេឡិចត្រូនិក៖** ស្របតាមនិន្នាការពិភពលោក និងយុទ្ធសាស្ត្រ និងការផ្តួចផ្តើមគំនិតក្នុងការធ្វើទំនើបកម្មឌីជីថលប្រព័ន្ធសេដ្ឋកិច្ច របស់រាជរដ្ឋាភិបាលកម្ពុជា ការបញ្ចូលទឹកប្រាក់តាមអេឡិចត្រូនិកនៅបន្តកើនឡើង ដែលបានបង្ហាញពីការកើនឡើង ១៤% បើធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣ ដែលចំនួនភាគច្រើននៃការបញ្ចូលទឹកប្រាក់សរុប។ ការចាប់នូវការធ្វើកម្មវិធីធនាគារ និងកាបូបចល័ត (Mobile Wallet) គឺជាកត្តាជំរុញដ៏សំខាន់នៃកំណើននេះ។ លើសពីនេះក្រុមហ៊ុន សែលកាត ក៏កំពុងដាក់ឲ្យដំណើរការ នូវសមត្ថភាពបញ្ចូលទឹកប្រាក់តាមអេឡិចត្រូនិកទៅកាន់បណ្តាលអ្នកចែកចាយលក់រាយ ដែលនឹងជំរុញឲ្យមានកំណើនជាបន្តបន្ទាប់ នៃការកើនឡើងនៃការបញ្ចូលទឹកប្រាក់តាមអេឡិចត្រូនិក។

### ២. ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ក្រុមហ៊ុនមិនមានវត្ថុធាតុដើមលើផលិតផល ឬសេវាកម្មនោះទេ។

### ៣. ការវិភាគលើពន្ធ

ក្រុមហ៊ុន ខេម ជីអេសអេម មានកាតព្វកិច្ចក្នុងការបង់ពន្ធជូនរាជរដ្ឋាភិបាល ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុន ខេម ជីអេសអេម ជាប់ជាអ្នកបង់ពន្ធធំ និងតម្រូវឲ្យបង់ពន្ធស្របតាមប្រព័ន្ធរបបពិត ដូចដែល

បានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។ ចំណាយពន្ធរួមមាន ពន្ធដែលបានបង់ក្នុងអំឡុងឆ្នាំសារពើពន្ធ និងពន្ធពន្យារពេល។ ការចំណាយលើពន្ធប្រាក់ចំណូលត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ/(ខាត)។

### ៤. ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

ក្នុងផ្នែកនេះ មិនមានធាតុពិសេសណាមួយ ដែលប៉ះពាល់ដល់ដំណើរការហិរញ្ញវត្ថុ ក្នុងកំឡុងត្រីមាសនេះឡើយ។

## គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

- ប្រាក់ចំណូលប្រចាំត្រីមាសទី៣ មានការកើនឡើងចំនួន ២% ស្មើនឹង ៤.០៥លាន ដោយសារចំណូលពីការបើកដំណើរការនៃ Sub & Win, Top Up & Win យុទ្ធនាការទីផ្សារ។ ការភ្ជាប់គម្រោង $១.៥ និងលើសពីការគ្រោងទុក ៦% និងការបញ្ចូលទឹកប្រាក់ $១.៥ បានកើនឡើងចំនួន ៣% ប្រៀបធៀបនឹងត្រីមាសទី២។
- ត្រីមាសទី៣ បានបង្ហាញពីការធ្លាក់ចុះនៃចំនួនអតិថិជន postpaid ចំនួន២% ហើយសេវាកម្មសែលកាតហូមវ៉ាយហ្វាយបានកើនឡើងចំនួន៦% ប្រៀបធៀបនឹងត្រីមាសទី២។ ការផ្តល់សេវាកម្មអ៊ីនធឺណិតតាមផ្ទះ របស់សែលកាត ត្រូវបានបើកដំណើរការជាថ្មីក្រោមឈ្មោះ សែលកាតហូមវ៉ាយហ្វាយកាលពីខែមេសា។
- សេវាកម្មមិនមែនទូរគមនាគមន៍នៅតែបន្តធ្លាក់ចុះខណៈដែលក្រុមហ៊ុនកំពុងតែព្យាយាមក្នុងការស្តារឡើងវិញចំពោះផ្អាក ការផ្តាច់ និង/ឬ ការមិនអនុញ្ញាតលើសេវាកម្ម និងពាក្យស្នើសុំ។
- កម្មវិធីផ្លាស់ប្តូរនៅតែបន្តដូចដែលបានគ្រោងទុក ជាមួយនឹងការធ្វើឲ្យប្រសើរប្រព័ន្ធ BSS ទាំងមូល បង្កើនប្រសិទ្ធភាពការប្រើប្រាស់ប្រេកង់ជាមួយនឹងការបិទ 3G។
- ទន្ទឹមនឹងបរិបទពិភពលោកថ្មី និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងការផ្តួចផ្តើមដើម្បីដំណើរការសេដ្ឋកិច្ចតាមបែបឌីជីថល ការបញ្ចូលទឹកប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក នៅតែបន្តកើនឡើងចំនួន ២% បើធៀបទៅនឹងត្រីមាសទី២ ឆ្នាំ២០២៤ ព្រមទាំងកើតឡើងចំនួន ១៤% ប្រៀបធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២៣ ដែលមានចំនួន ៦៤% នៃចំនួនបញ្ចូលទឹកប្រាក់សរុប។ ការដំណើរការនៃប្រតិបត្តិការតាមកម្មវិធីធនាគារ និង Wallet គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជួយជំរុញការកើនឡើង។ ក្រុមហ៊ុន សែលកាត កំពុងតែដាក់ចេញជាបន្តបន្ទាប់នូវសមត្ថភាព នៃការបញ្ចូលទឹកប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈបណ្តាញអ្នកចែកចាយបន្ត និងតាមរយៈកម្មវិធី Cellcard App ដែលនឹងក្លាយជាកត្តាជំរុញដ៏សំខាន់ សម្រាប់ការបញ្ចូលទឹកប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ក្នុងចំណោមអ្នកប្រើប្រាស់។

## ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ចំណូលពីការលក់ និងការទិញរបស់ក្រុមហ៊ុន ខេម ជីអេសអេម គឺភាគច្រើនត្រូវបានប្រើប្រាស់ជាលុយដុល្លារអាមេរិក (USD)។ ហេតុដូចនេះក្រុមហ៊ុន ខេម ជីអេសអេម មិនមានរងផលប៉ះពាល់ខ្លាំង ពីការប្រែប្រួលនៃអត្រាប្តូរប្រាក់បរទេសនៅត្រីមាសទី២ ឆ្នាំ២០២៤ នេះទេ។

កម្ចីរបស់ក្រុមហ៊ុន ខេម ជីអេសអេម ក៏ប្រកាន់យករបបអត្រាការប្រាក់អណ្តែត ដូច្នេះក្រុមហ៊ុន ខេម ជីអេសអេម នឹងបង់ការប្រាក់បន្ថែម ជាមួយនឹងការកើនឡើងនៃអត្រាទីផ្សារ។

## ង. ផលប៉ះពាល់នៃអតិផរណា

អតិផរណា គឺជាអត្រានៃការកើនឡើងថ្លៃ នៅក្នុងអំឡុងពេលជាក់លាក់មួយ។ ជាទូទៅអតិផរណា គឺជាវិធានការទូលំទូលាយ ដូចជាការកើនឡើងនៃថ្លៃ ឬការកើនឡើងនៃថ្លៃរស់នៅប្រចាំថ្ងៃ។ ជំងឺកូវីដ-១៩ បានជះឥទ្ធិពលយ៉ាង

ច្រើនដល់សេដ្ឋកិច្ចទូទាំងពិភពលោក រួមទាំងអតិផរណាផងដែរ។ សម្រាប់ប្រទេសកម្ពុជា ក្នុងឆ្នាំ ២០២២ យើងអាចឃើញថាអតិផរណាកើនឡើងដល់ ៥.៣៤% ដែលជាការកើនឡើង ២.៤% ធៀបនឹងឆ្នាំមុន។ នេះក៏បានជះឥទ្ធិពលដល់ការចំណាយលើឧបករណ៍ប្រើប្រាស់របស់ក្រុមហ៊ុនផងដែរ ដោយសារតម្លៃប្រេងបានកើនឡើងខ្លាំង។

អត្រាអតិផរណាជាមធ្យមនៅកម្ពុជា ត្រូវបានព្យាករណ៍ថានឹងកើនឡើងសរុបមួយភាគរយ ក្នុងរយៈពេលពីឆ្នាំ ២០២៣ ដល់ឆ្នាំ ២០២៨។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ទិសដៅសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានដឹកនាំដោយផែនការសេដ្ឋកិច្ចជាតិជាបន្តបន្ទាប់ និងគោលដៅសេដ្ឋកិច្ចសង្គម ក្នុងគោលបំណងឆ្ពោះទៅរកការក្លាយជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ពីជំងឺកូវីដ-១៩ គោលនយោបាយជាច្រើន ត្រូវបានណែនាំ ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ច ប្រកបដោយនិរន្តរភាពប្រហែល ៧% ជារៀងរាល់ឆ្នាំ ដើម្បីពង្រីកមូលដ្ឋានកំណើន និងលើកកម្ពស់ការប្រកួតប្រជែង ខណៈពេលដែលរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការលើកកម្ពស់គោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុដ៏ត្រឹមត្រូវ (លទ្ធផលសារពើពន្ធកម្ពុជា និងទិសដៅគោលនយោបាយ ការអនុវត្តម៉ាក្រូសេដ្ឋកិច្ចកម្ពុជា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២២)។ នៅឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុផ្សេងៗ ក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព ជំរុញការវិនិយោគ និងដោះស្រាយបញ្ហាប្រឈមសំខាន់ៗដែលប្រទេសកំពុងជួបប្រទះ។ គោលនយោបាយសំខាន់ៗមួយចំនួនរួមមានៈ

- ការធ្វើពិសោធកម្មសេដ្ឋកិច្ចៈ រដ្ឋាភិបាលបានបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើពិសោធកម្មសេដ្ឋកិច្ចលើសពីវិស័យប្រពៃណីដូចជា កសិកម្ម និងការផលិតសម្លៀកបំពាក់។ គោលនយោបាយ ត្រូវបានតម្រង់ឆ្ពោះទៅរកការលើកកម្ពស់វិស័យដូចជាទេសចរណ៍ ផលិតកម្ម សំណង់ និងសេវាកម្ម ដើម្បីកាត់បន្ថយការពឹងផ្អែកលើឧស្សាហកម្មសំខាន់ៗមួយចំនួន និងបង្កើតឱកាសការងារបន្ថែមទៀត។
- ការជម្រុញការវិនិយោគៈ ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (FDI) និង ជម្រុញការវិនិយោគក្នុងស្រុក រដ្ឋាភិបាលបានអនុវត្តគោលនយោបាយកែលម្អបរិយាកាសធុរកិច្ច សម្រួលដំណើរការបទប្បញ្ញត្តិ និងផ្តល់ការលើកទឹកចិត្តសម្រាប់អ្នកវិនិយោគ។ តំបន់សេដ្ឋកិច្ចពិសេស (SEZs) ត្រូវបានបង្កើតឡើងបន្ថែមទៀត ដើម្បីជួយសម្រួលដល់ការវិនិយោគ និងលើកកម្ពស់ឧស្សាហកម្មតម្រង់ទិសនាំចេញ។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធៈ រដ្ឋាភិបាលបានផ្តល់អាទិភាពដល់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ រួមទាំងការសាងសង់ផ្លូវថ្នល់ ការពង្រីកកំពង់ផែ និងការវិនិយោគលើវិស័យថាមពល។ គំនិតផ្តួចផ្តើមទាំងនេះមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវការតភ្ជាប់ សម្រួលពាណិជ្ជកម្ម និងលើកកម្ពស់ការប្រកួតប្រជែង របស់ប្រទេសនៅលើឆាកតំបន់ និងពិភពលោក។
- គោលនយោបាយសារពើពន្ធៈ វិធានការគោលនយោបាយសារពើពន្ធ ផ្តោតលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការកែលម្អការប្រមូលចំណូល និងការគ្រប់គ្រងការចំណាយសាធារណៈប្រកបដោយប្រសិទ្ធភាព។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីពង្រីកមូលដ្ឋានពន្ធ បង្កើនការអនុលោមតាមពន្ធ និងពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានានិរន្តរភាពសារពើពន្ធ។

- គោលនយោបាយរូបិយវត្ថុ៖ ធនាគារជាតិនៃកម្ពុជា (NBC) បានបន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយការប្រុងប្រយ័ត្ន សំដៅរក្សាស្ថិរភាពតម្លៃ និងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ វិធានការរួមមាន ការគ្រប់គ្រងអត្រាការប្រាក់ ការគ្រប់គ្រងសម្ពាធអតិផរណា និងការត្រួតពិនិត្យវិស័យធនាគារដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ។

- កម្មវិធីសុខុមាលភាពសង្គម៖ រាជរដ្ឋាភិបាលបានពង្រីកកម្មវិធីសុខុមាលភាពសង្គម ដើម្បីដោះស្រាយបញ្ហាកាត់បន្ថយភាពក្រីក្រ កែលម្អការថែទាំសុខភាព និងលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ។ ការវិនិយោគត្រូវបានធ្វើឡើងនៅក្នុងហេដ្ឋារចនាសម្ព័ន្ធសង្គម រួមទាំងកន្លែងថែទាំសុខភាព និងសាលារៀន ដើម្បីបង្កើនគុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេស។

- ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល៖ គោលនយោបាយត្រូវបានណែនាំដើម្បីលើកកម្ពស់ការអភិវឌ្ឍ សេដ្ឋកិច្ចឌីជីថល រួមទាំងពាណិជ្ជកម្មអេឡិចត្រូនិក ការទូទាត់តាមឌីជីថល និងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន។ គំនិតផ្តួចផ្តើមមានគោលបំណងជំរុញការបង្កើតថ្មី ភាពជាសហគ្រិន និងការដាក់បញ្ចូលឌីជីថល ដើម្បីទាញយកសក្តានុពលនៃបច្ចេកវិទ្យាសម្រាប់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម។

ក្នុងរយៈពេលមធ្យម និងវែង សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវបានគេព្យាករណ៍ ថានឹងបន្តពង្រីកជាមួយនឹងអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ៧% ស្រដៀងនឹងអត្រាកំណើននៅមុនការរាតត្បាតនៃជំងឺកូវីដ-១៩។ គោលនយោបាយសារពើពន្ធសំដៅ លើការប្រើប្រាស់ការចំណាយរបស់រដ្ឋាភិបាល និងពន្ធដារដើម្បីគ្រប់គ្រងសេដ្ឋកិច្ច។ ជាធម្មតា រដ្ឋាភិបាលប្រើប្រាស់គោលនយោបាយសារពើពន្ធ ដើម្បីលើកកម្ពស់កំណើនដ៏រឹងមាំ និងនិរន្តរភាព និងកាត់បន្ថយភាពក្រីក្រ។ នៅក្នុងប្រទេសកម្ពុជា គោលនយោបាយសារពើពន្ធគឺជាឧបករណ៍សំខាន់មួយ សម្រាប់លើកកម្ពស់កំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងផ្តល់នូវការជំរុញតម្រូវការរយៈពេលខ្លី ក្នុងបរិបទនៃសេដ្ឋកិច្ចដែលមានប្រាក់ដុល្លារខ្ពស់។ ជារួម គោលនយោបាយសេដ្ឋកិច្ចសារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ ២០២៤ ត្រូវបានតម្រង់ឆ្ពោះទៅរកការសម្រេចបាននូវការអភិវឌ្ឍ ប្រកបដោយបរិយាប័ន្ន និងនិរន្តរភាព ការលើកកម្ពស់ការប្រកួតប្រជែង និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។ គោលនយោបាយទាំងនេះបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការស្វែងរកបញ្ហាប្រឈម និងចាប់យកឱកាសនៅក្នុងបរិយាកាសសេដ្ឋកិច្ចសកលភាវូបនីយកម្ម និងថាមវន្តកាន់តែខ្លាំងឡើង។

រាជធានីភ្នំពេញ ថ្ងៃសុក្រ ១៥កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៤

បានអាន និងឯកភាព

ហត្ថលេខា

**អ្នកឧកញ៉ា គិត ម៉េង**

**ប្រធានក្រុមប្រឹក្សាភិបាល**

ក្រុមហ៊ុន ខេម ជីអេសអេម ម.ក

ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេលសម្រាប់រយៈពេល ៣ខែ និង៩ខែ បញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤




**ក្រុមហ៊ុន ខេម ជីអេសអេម ម.ក**

33 មហាវិថីព្រះសីហនុ ប្រអប់សំបុត្រ
2468 ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

+855 12 800 800
www.cellcard.com.kh

# ក្រុមហ៊ុន ខេម ជីអេសអេម ម.ក

## ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល
## សម្រាប់រយៈពេល ៣ខែ និង ៩ខែ បញ្ចប់
## នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤

**ក្រុមហ៊ុន ខេម ជីអេសអេម ម.ក**

**ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល**
**សម្រាប់រយៈពេល ៣ខែ និង ៩ខែ បញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤**

| **មាតិកា** | **ទំព័រ** |
|---|---|
| សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល | ២ - ៣ |
| របាយការណ៍ចំណេញឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបរួមចន្លោះពេល | ៤ - ៥ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបរួមចន្លោះពេល | ៦ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបរួមចន្លោះពេល | ៧ – ៨ |
| កំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល | ៩ – ២៦ |
| របាយការណ៍ស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល | ២៧ – ២៨ |

33 មហាវិថី ព្រះសីហនុ
ប្រអប់សំបុត្រ 2468 ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

33 Preah Sihanouk Blvd,
P.O. Box 2468, Phnom Penh,
Kingdom of Cambodia
+855 12 800 800
www.cellcard.com.kh

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាងនាមជំនួសឲ្យក្រុមប្រឹក្សាភិបាលនៃសម្ព័ន្ធ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល របស់ក្រុមហ៊ុន ខេមជីអេសអេម ម.ក និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (ហៅកាត់ជារួមថា "សម្ព័ន្ធ") គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២៤ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបរួមចន្លោះពេលសម្រាប់រយៈពេល៣ខែ និង៩ខែ ដែលបានបញ្ចប់របាយការណ៍បម្រែបម្រួលមូលធនសង្ខេបរួមចន្លោះពេល និងរបាយការណ៍លំហូរសាច់ប្រាក់សង្ខេបរួមចន្លោះពេលសម្រាប់ រយៈពេល៩ខែ ដែលបានបញ្ចប់ និងកំណត់សម្គាល់ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល (ត្រូវបានគេស្គាល់ជារួមថា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល") ត្រូវបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា លេខ៣៤ ស្តីពី "របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល "។

ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ខេម ជីអេសអេម ម.ក CAMGSM PLC KINGDOM OF CAMBODIA

លោក Simon Perkins
នាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៖ 12 NOV 2024

## **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល**
## **គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤**

| | | មិនបានធ្វើសវនកម្ម | | បានធ្វើសវនកម្ម | |
|---|---|---|---|---|---|
| | កំណត់ | ៣០ កញ្ញា ២០២៤ | | ៣១ ធ្នូ ២០២៣ | |
| | សម្គាល់ | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល |
| | | *បានត្រួតពិនិត្យរួច* | | | |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៦ | ៩៨.៦២០.៣២៣ | ៤០០.៤៩៧ | ៨៦.៩៨៦.០៣៥ | ៣៥៥.៣៣៨ |
| ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | | ១២០.០៩៩.២៤០ | ៤៨៧.៧២៣ | ១១០.៥៧២.២០៩ | ៤៥១.៦៨៧ |
| ទ្រព្យសកម្មអរូបី | | ១.៦១៨.៤៧៣ | ៦.៥៧៣ | ១.៨៥៨.៣៥៥ | ៧.៥៩១ |
| បុរេប្រទានឱ្យអ្នកផ្គត់ផ្គង់សម្រាប់ការទិញ ទ្រព្យសកម្ម | ៧ | ១០.០៣០.៣៨៣ | ៤០.៧៣៣ | ៦.៦២៥.៤១៨ | ២៧.០៦៥ |
| ប្រាក់កក់ដែលអាចបង្វិលមកវិញបាន | | ៥១៦.២០០ | ២.០៩៦ | ៥១៦.២០០ | ២.១០៩ |
| ឥណទានផ្តល់ឱ្យភាគីពាក់ព័ន្ធ | ៨ | - | - | ៣៨៦.១៩៩.៥១៣ | ១.៥៧៧.៦២៥ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | ២៣០.៨៨៤.៦១៩ | ៩៣៧.៦២២ | ៥៩២.៧៥៧.៧៣០ | ២.៤២១.៤១៥ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| ចំណាយបង់មុន និងប្រាក់កក់ | | ២.៨៧៩.០០៨ | ១១.៦៩២ | ៣.៥២៦.១០៩ | ១៤.៤០៤ |
| សន្និធិ | | ៨៧៦.៣៧០ | ៣.៥៥៧ | ៧៧១.០៦៧ | ៣.១៥០ |
| ឥណទានផ្តល់ឱ្យភាគីពាក់ព័ន្ធ | ៨ | ៣៨៦.១៩៩.៥១៣ | ១.៥៦៨.៣៥៦ | - | - |
| គណនីត្រូវទទួលពីភាគីពាក់ព័ន្ធ | | ៦០៤.៣៧៦ | ២.៤៥៤ | ២៨.៣៧៧ | ១១៥ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជន ផ្សេងៗ | | ៤.៤១៩.២៧១ | ១៧.៩៤៧ | ៣.៥៤២.៣៨១ | ១៤.៤៧១ |
| ប្រាក់បញ្ញើមានកាលកំណត់ | ៩ | ៣.០០០.០០០ | ១២.១៨៣ | - | - |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១០ | ៤២.៧៤៩.៩២៩ | ១៧៣.៦០៧ | ២៦.៣០១.៣៧១ | ១០៧.៤៤១ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | ៤៤០.៧២៨.៤៦៧ | ១.៧៨៩.៧៩៦ | ៣៤.១៦៩.៣០៥ | ១៣៩.៥៨១ |
| **ទ្រព្យសកម្មសរុប** | | **៦៧១.៦១៣.០៨៦** | **២.៧២៧.៤១៨** | **៦២៦.៩២៧.០៣៥** | **២.៥៦០.៩៩៦** |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | | ១៤៦.៩៤៥.៣៤០ | ៥៩៦.៧៤៥ | ១៤៦.៩៤៥.៣៤០ | ៦០០.២៧២ |
| បុព្វលាភភាគហ៊ុន | | ២.៥៥៣.៩០៧ | ១០.៣៧១ | ២.៥៥៣.៩០៧ | ១០.៤៣៣ |
| ចំណេញរក្សាទុក | | ១៤១.៧០៤.០១៤ | ៥៧៣.៨០៩ | ១២០.៦២៥.២០៨ | ៤៨៧.៨០៧ |
| លម្អៀងពីការប្រែសម្រួលរូបិយប័ណ្ណ | | - | ១.៦៥១ | - | ៤.៩៤៦ |
| **មូលធនសរុប** | | **២៩១.២០៣.២៦១** | **១.១៨២.៥៧៦** | **២៧០.១២៤.៤៥៥** | **១.១០៣.៤៥៨** |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| បំណុលភតិសន្យា | | ៣៧.៦១២.៤៨៣ | ១៥២.៧៤៤ | ៣០.៦០៧.៤៩០ | ១២៥.០៣២ |
| ពន្ធពន្យារលើប្រាក់ចំណូលជាបំណុល-សុទ្ធ | | ៨.២១៥.៩៣៤ | ៣៣.៣៦៥ | ៩.៥៧៨.៨៧៣ | ៣៩.១៣០ |
| ប្រាក់កម្ចី | ១១ | ១៧១.០១១.៤០៥ | ៦៩៤.៤៧៧ | ១៣២.៧៩៧.៦៩២ | ៥៤២.៤៧៩ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | ១២ | ២.៣៧៤.០៩៤ | ៩.៦៤១ | ១.២១៤.៦៥១ | ៤.៩៦២ |
| មូលបត្របំណុល | | ១៩.៥១៧.១៦៥ | ៧៩.២៥៩ | ១៩.៥១៩.៥៤៦ | ៧៩.៧៣៧ |
| កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់អតីតភាពការងារ | | ៤៤៦.៤២៤ | ១.៨១៣ | ៦៣៥.៨១៨ | ២.៥៩៧ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នក ផ្គត់ផ្គង់ផ្សេងៗ | | - | - | ៣.៨៥២.០២៤ | ១៥.៧៣៦ |
| **បំណុលរយៈពេលវែងសរុប** | | ២៣៩.១៧៧.៥០៥ | ៩៧១.២៩៩ | ១៩៨.២០៦.០៩៤ | ៨០៩.៦៧៣ |

**ក្រុមហ៊ុន ខេម ឌីអេសអេម ម.ក**

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេល (ត)**
**គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤**

| | | មិនបានធ្វើសវនកម្ម | | បានធ្វើសវនកម្ម | |
|---|---|---|---|---|---|
| | កំណត់ | ៣០ កញ្ញា ២០២៤ | | ៣១ ធ្នូ ២០២៣ | |
| | សម្គាល់ | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល |
| | | *បានត្រួតពិនិត្យរួច* | | | |
| **បំណុលរយៈពេលខ្លី** | | | | | |
| បំណុលភតិសន្យា | | ១២.០៧១.៧២៩ | ៤៩.០២៣ | ៨.០៧៩.៤៨៣ | ៣៣.០០៥ |
| បំណុលក្នុងកិច្ចសន្យា | | ២៥.៩៣១.៨៩៨ | ១០៥.៣០៩ | ២២.៩៦៤.០៥៦ | ៩៣.៨០៨ |
| បំណុលបង្គរ | | ៣០.៤៤០.៩៤៦ | ១២៣.៦២១ | ៣៨.៨៣៧.៣៣៨ | ១៥៨.៦៥១ |
| បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | | ៥.០៨២.៥២៧ | ២០.៦៤០ | ៨.៧៤៦.០១០ | ៣៥.៧២៧ |
| ប្រាក់កម្ចី | ១១ | ១៥.៦១២.៧៤១ | ៦៣.៤០៣ | ១២.៥២៥.៤៩៩ | ៥១.១៦៧ |
| បំណុលហិរញ្ញវត្ថុផ្សេងៗ | ១២ | ៤.៧១១.៩៦៩ | ១៩.១៣៥ | ៩.៤១៣.៧៥៩ | ៣៨.៤៥៥ |
| មូលបត្របំណុល | | ៥៨៣.៦៩៥ | ២.៣៧០ | ១៤៧.១៤៩ | ៦០០ |
| កាតព្វកិច្ចការទូទាត់ប្រាក់បំណាច់ អតីតភាពការងារ | | ១៦៧.៤២៨ | ៦៨០ | ៤៧.២៨៥ | ១៩៣ |
| ទឹកប្រាក់ត្រូវសងភាគីពាក់ព័ន្ធ | | ២.៨៦០.០៥២ | ១១.៦១៥ | ៦.៣៥២.០៤១ | ២៥.៩៤៨ |
| ទឹកប្រាក់ត្រូវបង់សម្រាប់ការទិញ ទ្រព្យសកម្ម | | ៥.១៥៩.៤៣៩ | ២០.៩៥២ | ៤៩៨.៦៨៧ | ២.០៣៧ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និង គណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | | ៣៨.៦០៩.៨៩៦ | ១៥៦.៧៩៥ | ៥០.៩៨៥.១៧៩ | ២០៨.២៧៤ |
| **បំណុលរយៈពេលខ្លីសរុប** | | ១៤១.២៣២.៣២០ | ៥៧៣.៥៤៣ | ១៥៨.៥៩៦.៤៨៦ | ៦៤៧.៨៦៥ |
| **បំណុលសរុប** | | **៣៨០.៤០៩.៨២៥** | **១.៥៤៤.៨៤២** | **៣៥៦.៨០២.៥៨០** | **១.៤៥៧.៥៣៨** |
| **មូលធន និងបំណុលសរុប** | | **៦៧១.៦១៣.០៨៦** | **២.៧២៧.៤១៨** | **៦២៦.៩២៧.០៣៥** | **២.៥៦០.៩៩៦** |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកនៃព័ត៌មានហិរញ្ញវត្ថុសង្ខេបរួមចន្លោះពេលនេះ។

## ក្រុមហ៊ុន ខេម ឌីអេសអេម ម.ក

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបរួមចន្លោះពេល
## សម្រាប់រយៈពេល ៣ខែ និង ៩ខែ បញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤

| | | មិនបានធ្វើសវនកម្ម | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | សម្រាប់រយៈពេល ៣ខែ ដែលបានបញ្ចប់ | | | | សម្រាប់រយៈពេល ៩ខែ ដែលបានបញ្ចប់ | | | |
| | កំណត់ | ៣០ កញ្ញា ២០២៤ | | ៣០ កញ្ញា ២០២៣ | | ៣០ កញ្ញា ២០២៤ | | ៣០ កញ្ញា ២០២៣ | |
| | សម្គាល់ | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល | ដុល្លារអាមេរិក | លានរៀល |
| | | *បានត្រួតពិនិត្យរួច* | | *បានរាយការណ៍ឡើងវិញ (កំណត់សម្គាល់ទី ២០)* | | *បានត្រួតពិនិត្យរួច* | | *បានរាយការណ៍ឡើងវិញ (កំណត់សម្គាល់ទី ២០)* | |
| **ចំណូល** | | ៤២.៥៦៦.៦៣៩ | ១៧៤.០១២ | ៤៥.០៣៦.៩៣៩ | ១៨៦.០៩៣ | ១២៩.៤៣១.៦៦៨ | ៥២៨.០៨១ | ១៣៦.៤១៤.០៨៧ | ៥៦០.២៥៣ |
| **ចំណាយប្រតិបត្តិការ** | | | | | | | | | |
| ចំណាយប្រតិបត្តិការផ្សេងៗ | ១៣ | (២១.២១០.៤០៨) | (៨៦.៧០៨) | (១៩.៦១១.៣៥២) | (៨១.០៣៤) | (៥៩.២៨៦.២៣០) | (២៤១.៨៨៨) | (៦០.៧៦៧.២០៨) | (២៤៩.៥៧១) |
| រំលស់ | | (៨.២៩០.៥១២) | (៣៣.៨៩២) | (៩.៤៣២.៣៧០) | (៣៨.៩៧៥) | (២៦.៩៩៧.៥៨៨) | (១១០.១៥០) | (២៧.៥៨៨.៨៩៦) | (១១៣.៣០៨) |
| ចំណាយបុគ្គលិក | | (៣.៩៧០.៧៣៣) | (១៦.២៣២) | (៣.៤៤១.៧៣៧) | (១៤.២២១) | (៩.០៧៣.០៣១) | (៣៧.០១៨) | (៩.៩៧៣.០៨០) | (៤០.៩៥៩) |
| ចំណាយភ្ជាប់បណ្ដាញទូរស័ព្ទឆ្លងប្រព័ន្ធ | | (៧៥៤.៥៦២) | (៣.០៨៥) | (៧៥៨.២២៤) | (៣.១៣៣) | (២.៣០៥.៨៧៤) | (៩.៤០៨) | (២.២០៤.៧០៧) | (៩.០៥៥) |
